ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១០៤ MOC / M 2005

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្មតាមជើងយន្តហោះទៅសហរដ្ឋអាមេរិក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- តាមតំរូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ឬ វិក័យប័ត្រពាណិជ្ជកម្មសំរាប់នាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកតាមជើងយន្តហោះត្រូវអនុវត្តនៅក្រោយពេលទំនិញបាននាំចេញផុតពីកម្ពុជា ។

**ប្រការ ២ :** ឯកសារយោងភ្ជាប់ដើម្បីស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ឬវិក័យប័ត្រពាណិជ្ជកម្មមានដូចខាងក្រោម :

- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" និង ទីចាត់ការគយ និង រដ្ឋាករ ។
- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមយន្តហោះ (Air Waybill)
- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់ (Sale Contract)
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល និង ***កំរៃការនាំចេញ*** (Export Management Fee) ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គនាយកបច្ចេកទេស, អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ, អគ្គាធិការ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ, ប្រធាននាយកដ្ឋានរដ្ឋបាល, ប្រធាននាយកដ្ឋានគណនេយ្យ, ប្រធាននាយកដ្ឋានកាំកុងត្រូល, និង នាយិកាខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន:</u>**

- ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង** (ណាំហុង)
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- អគ្គប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- ទីចាត់ការគយ និង រដ្ឋាករ
- ដូចក្នុងប្រការ ៤
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708